**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):19-Oct-2012, 13:45
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ១២ តុលា ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងឯកសារដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលលោកស្រី ELIZABETH BECKER**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី អៀង សារី**
អាង ឧត្តម
Michael G. KARNAVAS

**ចម្លងជូន÷**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង÷**
ចៅក្រម **និល ណុន**
ចៅក្រម **យ៉ុរ ឧត្តរា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **ធូ មុន្នី**

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវី ("មេធាវីការពារក្តី") របស់គាត់ លោក អៀង សារី ដោយអនុលោមតាមវិធាន ៨៧ (៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") ស្នើសុំដាក់ឯកសារវិវេចនា (book review) របស់សាស្ត្រាចារ្យ David Chandler ដែលមានចំណងជើងថា *Requiem for the 1970s* នៅក្នុងសៀវភៅ *របស់ Elizabeth Becker* ដែលមានចំណងជើងថា When The War Was Over *(នៅពេលដែលសង្គ្រាមរលត់ទៅ)* ជូនអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសដើម្បីប្រើប្រាស់វិវេចនានេះក្នុងអំឡុងពេលសួរដេញដោលលោកស្រី Becker។ សំណើនេះមានភាពចាំបាច់ ដោយហេតុថា វិវេចនានេះជាឯកសារពាក់ព័ន្ធ មានតម្លៃជាភស្តុតាង និងចាំបាច់សម្រាប់បញ្ជាក់ការពិតក្នុងសំណុំរឿង ០០២/០១។ ក្នុងការអនុវត្តការងារដោយយកចិត្តទុកដាក់ត្រឹមត្រូវរបស់ខ្លួន មេធាវីការពារក្តីបានចាប់ផ្តើមស្វែងរកសម្ភារៈឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាស្ត្រាចារ្យ Chandler និងលោកស្រី Becker រួមទាំងឯកសារនេះផង នៅពេលដែលឃើញមានផែនការពិតប្រាកដថា សាស្ត្រាចារ្យ Chandler និងលោកស្រី Becker អាចត្រូវបានកោះហៅជាសាក្សីក្នុងសំណុំរឿង ០០២។ ថ្វីបើមេធាវីការពារក្តីបានខិតខំខ្នះខ្នែងអស់ពីលទ្ធភាពក៏ដោយ ក៏មេធាវីទើបតែបានរកឃើញសំណៅថតចម្លងនៃឯកសារនេះកាលពីពេលថ្មីៗកន្លងទៅនេះប៉ុណ្ណោះ។ ឯកសារនេះបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) ព្រោះថា ៖ **ក.** ឯកសារនេះជាឯកសារពាក់ព័ន្ធ និងមិនច្រំដែល **ខ.** ឯកសារនេះរកបានក្នុងរយៈពេលសមស្រប **គ.** ឯកសារនេះសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅ **ឃ.** ឯកសារនេះត្រូវបានច្បាប់អនុញ្ញាត **ង.** ឯកសារនេះពុំមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ទេ។ មេធាវីការពារក្តីពុំមានវិវេចនានេះនៅមុនពេលចាប់ផ្តើមនៃសវនាការឡើយ។ ការទទួលយកឯកសារនេះនឹងមិនធ្វើឱ្យភាគីណាមួយរងព្យសនកម្មឡើយ ដោយហេតុថាភាគីមានពេលវេលាច្រើនដើម្បីពិនិត្យមើល និងវាយតម្លៃឯកសារនេះ មុនពេលលោកស្រី Becker ផ្តល់សក្ខីកម្មនោះ។

## I. អង្គហេតុពាក់ព័ន្ធ

1. កាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ក.ស.ព បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០២ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានយោងទៅសាស្ត្រាចារ្យ Chandler និងលោកស្រី Becker ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានជាច្រើនរបស់ខ្លួន[1]។ ក្រុមមេធាវីការពារក្តីលោក អៀង សារី ត្រូវបានបង្កើតឡើងក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៧[2]។ ភ្លាមៗបន្ទាប់ពីការ

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារលេខ D3 ។

[2] *សូមមើល* សេចក្តីសម្រេចទទួលស្គាល់មេធាវី ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ D36។

បង្កើតក្រុមមេធាវីនេះ ជាផ្នែកមួយនៃកិច្ចខិតខំយកចិត្តទុកដាក់ត្រឹមត្រូវរបស់ខ្លួន មេធាវីការពារក្ដីបានចាប់ផ្ដើមពិនិត្យមើល និងវិភាគអំពីដីកាសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ និងប្រភពនានាដែលបានលើកនៅជើងទំព័រនៃដីកានេះ រួមទាំងសម្រង់ចេញពីសៀវភៅរបស់សាស្ត្រាចារ្យ Chandler និងលោកស្រី Becker។ នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ មេធាវីការពារក្ដីបានជួលប្រវត្តិវិទូឈ្មោះ Michael Vickery មកធ្វើជាអ្នកពិគ្រោះយោបល់ជំនាញមួយរូប។ ក្នុងពេលរៀបចំយុទ្ធសាស្ត្រ និងត្រៀមរៀបចំសម្រាប់ការសួរដេញដោលដែលអាចមានចំពោះសាស្ត្រាចារ្យ Chandler និង/ឬ លោកស្រី Becker មេធាវីការពារក្ដីបានដឹងថា សាស្ត្រាចារ្យ Vickery មានឯកសារវិវេចនាមួយរបស់សាស្ត្រាចារ្យ Chandler អំពីសៀវភៅរបស់លោកស្រី Becker ដែលមានចំណងជើងថា *When The War Was Over* (នៅពេលដែលសង្គ្រាមរលត់ទៅ)។

2. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ សាស្ត្រាចារ្យ Vickery បានផ្ញើសារអេឡិចត្រូនិកមួយទៅសាស្ត្រាចារ្យ Chandler ដើម្បីស្នើសុំកាលបរិច្ឆេទ និងទីកន្លែងនៃការបោះពុម្ពផ្សាយឯកសារវិវេចនារបស់គាត់នេះ ដោយហេតុថាឯកសារវិវេចនារបស់សាស្ត្រាចារ្យ Vickery ពុំមានព័ត៌មាននេះ[3]។ សាស្ត្រាចារ្យ Chandler បានឆ្លើយតបថា វិវេចនារបស់គាត់ត្រូវបានបោះពុម្ពផ្សាយក្នុងព្រឹត្តិប័ត្រ *Indo-China Issues* ក្នុងឆ្នាំ ១៩៨៦[4]។

3. នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ ដោយកត់សម្គាល់ឃើញថា ទម្រង់នៃវិវេចនារបស់គាត់ ពុំដូចទៅនឹងទម្រង់ទូទៅនៃព្រឹត្តិប័ត្រ *Indo-China Issues* សាស្ត្រាចារ្យ Vickery បានស្នើសុំការបំភ្លឺពីសាស្ត្រាចារ្យ Chandler អំពីទីកន្លែងនៃការបោះពុម្ពផ្សាយព្រឹត្តិប័ត្រនេះ[5]។ សាស្ត្រាចារ្យ Chandler បានឆ្លើយតបថា គាត់ជឿជាក់ថា ព្រឹត្តិប័ត្រនេះមានឈ្មោះថា *Indo-China Issues* ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់នឹងពិនិត្យមើលសំណុំឯកសាររបស់សាកលវិទ្យាល័យ Monash[6]។ សាស្ត្រាចារ្យ Chandler ហាក់ដូចជាពុំបានពិនិត្យមើលសំណុំឯកសាររបស់សាកលវិទ្យាល័យ Monash ឡើយ ពីព្រោះគាត់ពុំបានផ្ដល់ព័ត៌មានបន្ថែមណាមួយឡើយពាក់ព័ន្ធនឹងវិវេចនារបស់គាត់នោះ។

---

[3] សារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Vickery ផ្ញើជូនសាស្ត្រាចារ្យ Chandler ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០០៨ ។

[4] សារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Chandler ផ្ញើជូនសាស្ត្រាចារ្យ Vickery ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០០៨ ។

[5] សារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Vickery ផ្ញើជូនសាស្ត្រាចារ្យ Chandler ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៨ ។

[6] សារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Chandler ផ្ញើជូនសាស្ត្រាចារ្យ Vickery ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៨ ។

4. នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ក.ស.ព បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ស្តាប់សក្ខីកម្ម របស់សាស្ត្រាចារ្យ Chandler និងលោកស្រី Becker ក្នុងនាមជាសាក្សីជំនាញ[7]។ មេធាវីការពារក្តី បានចាប់ផ្តើមរៀបចំចម្លើយតប និងបញ្ជីឈ្មោះសាក្សីរបស់ខ្លួន។ មេធាវីការពារក្តីរំពឹងថានឹងប្រើវិវេចនារបស់សាស្ត្រាចារ្យ Chandler សម្រាប់ការសួរដេញដោលសាស្ត្រាចារ្យ Chandler និង/ឬ លោកស្រី Becker ប្រសិនបើពួកគាត់ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងចន្លោះពេលពីខែ មករា ឆ្នាំ ២០០៨ ដល់ខែ មករា ឆ្នាំ ២០១១ សាស្ត្រាចារ្យ Vickery បានវង្វេងបាត់វិវេចនារបស់សាស្ត្រាចារ្យ Chandler ។ សាស្ត្រាចារ្យ Vickery និងមេធាវីការពារក្តី បានព្យាយាមស្វែងរកសំណៅថតចម្លងនៃវិវេចនានេះ តាមរយៈការស្រាវជ្រាវតាមប្រព័ន្ធអិនធឺណិត និងមូលដ្ឋានទិន្នន័យបណ្ណាល័យនៅក្នុង សហរដ្ឋអាមេរិក និងអូស្ត្រាលី រួមទាំងបណ្ណសារនៃព្រឹត្តិប័ត្រ *Indo-China Issues* ផងដែរ។ ការស្រាវជ្រាវទាំងនេះពុំ បានទទួលជោគជ័យឡើយ។

5. ក្នុងខែ មិថុនា ឆ្នាំ ២០១២ មុនពេលសាស្ត្រាចារ្យ Chandler ផ្តល់សក្ខីកម្មតាមការគ្រោងទុក មេធាវីការពារក្តីបានស្នើសុំការអនុញ្ញាតដើម្បីប្រើប្រាស់វិវេចនារបស់គាត់ ក្នុងអំឡុងពេលសួរដេញដោលសាស្ត្រាចារ្យ Chandler[8]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តីសុំដាក់វិវេចនានេះជាភស្តុតាង ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងពុំអាចវាយតម្លៃអំពីភាពពាក់ព័ន្ធនៃវិវេចនាបានឡើយ ពីព្រោះថាមេធាវីការពារក្តីពុំទាន់បានរកឃើញឯកសារនេះនៅឡើយ[9]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ទៀតថា ឯកសារនេះបានស្ថិតនៅក្នុង

---

[7] បញ្ជីឈ្មោះអ្នកជំនាញ ក.ស.ព តាមវិធាន ៨០, បញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់ ១, ២,៣, ៣ ក, ៤ និង ៥ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9/4.2 ។

[8] សំណើសុំរបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ទាក់ទិននឹងឯកសារដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ E172/24/3 កថាខណ្ឌ ៧។

[9] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំផ្តល់ឯកសារក្នុងសំណុំរឿង ០០២ ទៅអ្នកជំនាញ និងសំណើរបស់ អៀង សារី ដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងឯកសារ ដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler (ឯកសារលេខ E172/24/2និង E172/24/3) " ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១២ ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២") ឯកសារលេខ E172/24/4 កថាខណ្ឌ ៧។

មជ្ឈដ្ឋានសាធារណៈចាប់តាំងពីឆ្នាំ ១៩៨៦ មកម្ល៉េះ[10]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា "ប្រសិនបើឯកសារនេះត្រូវបានរកឃើញទាន់ពេលវេលាក៏ដោយ ក៏ឯកសារនេះអាចត្រូវបានប្រើប្រាស់សម្រាប់តែការសួរសំណួរទៅអ្នកជំនាញប៉ុណ្ណោះ ហើយស្ថិតនៅក្រោមលក្ខខណ្ឌដូចខាងលើដដែល [ដូចជា ការប្រើប្រាស់វិវេចនានេះដើម្បីបង្កើតសំណួរ និងការជូនដំណឹងក្រៅផ្លូវការជាមុនឲ្យបានទាន់ពេលវេលា មកអង្គជំនុំជម្រះសាលាដំបូង និងភាគី]"[11]។

6. ចាប់ពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ដល់ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ សាស្ត្រាចារ្យ Chandler បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងនាមជាសាក្សីអ្នកជំនាញ។ គាត់បានផ្តល់សក្ខីកម្មលើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[12]។ មេធាវីការពារក្តីបានបន្តការស្វែងរកសំណៅថតចម្លងនៃវិវេចនានេះ។

7. កាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១២ សាស្ត្រាចារ្យ Vickery បានប្រទះឃើញ វិវេចនារបស់សាស្ត្រាចារ្យ Chandler នៅក្នុងបណ្ណសាររបស់គាត់នៅឈៀងម៉ៃ ប្រទេសថៃ[13]។ នៅពេលបានទទួលសំណៅថតចម្លងនៃវិវេចនានេះ មេធាវីការពារក្តីបានចាប់ផ្តើមដាក់ឯកសារនេះជាបន្ទាន់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង និងភាគី ពិនិត្យមើល[14] និងបកប្រែជាភាសាខ្មែរ និងភាសាបារាំង។

[10] *ដូចខាងលើដដែរ*, កថាខណ្ឌ ៧។

[11] *ដូចខាងលើដដែរ* ។

[12] *សូមមើល* ប្រតិចារិក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ឯកសារលេខ E1/92.1, *សូមមើល* ប្រតិចារិក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ E1/93.1, *សូមមើល* ប្រតិចារិក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១២ ឯកសារលេខ E1/94.1, *សូមមើល* ប្រតិចារិក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១២ ឯកសារលេខ E1/95.1 ប្រតិចារិក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១២ ឯកសារលេខ E1/96.1, ប្រតិចារិក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១២ ឯកសារលេខ E1/92.1។

[13] សារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Vickery ផ្ញើជូនអ្នកពិគ្រោះផ្នែកច្បាប់ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១២ និងសារអេឡិចត្រូនិករបស់សាស្ត្រាចារ្យ Vickery ផ្ញើជូនអ្នកពិគ្រោះផ្នែកច្បាប់ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២។

[14] វិវេចនារបស់សាស្ត្រាចារ្យ David Chandler សរសេរជាភាសាអង់គ្លេស ត្រូវបានបកប្រែជាភាសាខ្មែរ និងភាសាបារាំង និងបានដាក់ក្នុងថតដាក់ឯកសាររួម ERN ជាអង់គ្លេស 0085033-00850336 និង ERN ជាភាសាខ្មែរ 00852445-00852452 និង ERN ជាភាសាបារាំង 00852981-00852987។ ដើម្បីផ្តល់ភាពងាយស្រួលដល់អង្គជំនុំជម្រះ និងភាគី សូមភ្ជាប់អត្ថបទវិវេចនាសៀវភៅនេះទាំងបីភាសា។ *សូមមើល* ពិធីសារ "ឃ្លាំងទុកឯកសាររួម" ដែលបញ្ជាក់ថាឯកសារនេះ មិនទាន់បានវិភាគពីភាពជាប់ទាក់ទងនឹងសំណុំរឿងនេះទេ ប៉ុន្តែអាចមានព័ត៌មានដោះបន្ទុក និងដាក់បន្ទុក។ ឯកសារនេះ អាចដាក់ក្នុងឃ្លាំងផ្ទុកឯកសាររួមដើម្បីឲ្យភាគីទាំងអស់មានលទ្ធភាពពិនិត្យមើលបាន (កថាខណ្ឌ១-២)។

## II. ច្បាប់ និងទឡ្ហីករណ៍

8. លោកស្រី Elizabeth Becker ពុំមែនជាអ្នកជំនាញស្តីពីរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ នេះគឺជាបញ្ហាមួយដែលមេធាវីការពារក្តីបានលើកឡើងម្តងហើយម្តងទៀត[15] និងត្រូវបានបញ្ជាក់អះអាងដោយសាស្ត្រាចារ្យ Chandler ដែលជាអ្នកជំនាញជើងចាស់នៃប្រវត្តិសាស្ត្រកម្ពុជា[16] នៅក្នុងវិវេចនារបស់គាត់អំពីសៀវភៅរបស់លោកស្រី Becker។ បន្ទាប់ពីបានអានសៀវភៅរបស់លោកស្រី Becker សាស្ត្រាចារ្យ Chandler បានរកឃើញថា៖ **ក.** លោកស្រី Becker ពុំបានធ្វើការស្រាវជ្រាវទូលំទូលាយ ឬស្រាវជ្រាវដោយខ្លួនឯងឡើយ[17] **ខ.** គាត់បានពឹងផ្អែកយ៉ាងច្រើនលើស្នាដៃរបស់អ្នកដទៃ[18] **គ.** គាត់ពុំបានតែងតែបង្ហាញប្រភពរបស់អ្នកនិពន្ធ[19] និង **ឃ.** កង្វះភាពស្ទាត់ជំនាញរបស់គាត់អំពីភាសាខ្មែរ ធ្វើឱ្យគាត់សរសេរពុំបានល្អត្រង់ផ្នែកស្តីពីប្រវត្តិសាស្ត្រ[20]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកលោកស្រី Becker ជាសាក្សីអ្នកជំនាញ[21] បើទោះបីជាគាត់ជាអ្នកសារព័ត៌មានដែលពុំមានសញ្ញាប័ត្រពាក់ព័ន្ធ ដែលគ្រាន់តែបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ ដោយក្នុងសៀវភៅមានវិការៈជាក់ស្តែងនៅក្នុងវិធីសាស្ត្រ និងខ្លឹម

---

[15] *សូមមើល* សំណើសុំបំពេញកិច្ចស៊ើបសួរទីពីររបស់ អៀងសារី ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥ ដកស្រង់អត្ថបទរបស់ David Chandler ភ្លេងខ្លងខែកសម្រាប់ទសវត្សរ៍ឆ្នាំ ១៩៧០៖ Elizabeth Becker "នៅពេលដែលសង្គ្រាមរលត់ទៅ" លេខឥណ្ឌូចិន ឆ្នាំ១៩៨៦, ព័ត៌មានផ្តល់ដោយ Michael Vickery , ការជំទាស់ជាបឋមរបស់ លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ (ការជំទាស់ជាបឋមរបស់ លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញ) ឯកសារលេខ E9/4/9 កថាខណ្ឌ ១៥-១៦។ *សូមមើលផងដែរ* សេចក្តីសង្កត្សមរបស់លោក អៀង សារី ស្តីពីសាក្សី និងអ្នកជំនាញមួយចំនួនដែលសហាព្រះរាជអាជ្ញា, ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នួន ជាបានស្នើសុំកោះហៅ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១១ ឯកសារលេខ E93/12 កថាខណ្ឌ ១៩ លើកឡើងថាអ្នកស្រី Becker នមែនជាអ្នកជំនាញទេ។

[16] Phillip Short, The History of A Nightmare [ប៉ុល ពត៖ ប្រវត្តិសាស្ត្រនៃសុបិនអាក្រក់មួយ] (John Murray ឆ្នាំ ២០០៥) ឯកសារលេខ E3/9។

[17] David Chandler ភ្លេងខ្លងខែកសម្រាប់ទសវត្សរ៍ឆ្នាំ ១៩៧០៖ Elizabeth Becker "នៅពេលដែលសង្គ្រាមរលត់ទៅ" ឆ្នាំ ១៩៨៦ នៅទំព័រ ២ និង ៥ (វិវេចនាដោយ Chandler)។

[18] *ដូចខាងលើដែរ* នៅទំព័រ ៣,៥ និង៧ ។

[19] *ដូចខាងលើដែរ* នៅទំព័រ ២,៧។

[20] *ដូចខាងលើដែរ* នៅទំព័រ ៧។

[21] សេចក្តីសម្រេចតែងតាំងអ្នកជំនាញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ E215។

សារក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកភស្តុតាងណាមួយដែលកំណត់អំពីភាពអាចជឿជាក់បានទៅលើលោកស្រី Becker ក្នុងនាមជាសាក្សីអ្នកជំនាញ និងសុចរិតភាពនៃស្នាដៃរបស់គាត់ ដូចជាវិវេចនារបស់សាស្ត្រាចារ្យ Chandler អំពីសៀវភៅរបស់លោកស្រី Becker ថាជាភស្តុតាងដែលពាក់ព័ន្ធ និងដែលមានតម្លៃបញ្ជាក់អង្គហេតុក្នុងសំណុំរឿង ០០២/០១។

9. ដោយអនុលោមតាមវិធាន ៨៧(៣) ភស្តុតាងត្រូវតែបានទទួលយក ដរាបណាភស្តុតាងនោះជាភស្តុតាងពាក់ព័ន្ធ និងពុំច្រំដែល ដែលត្រូវបានទទួលក្នុងពេលសមស្រប និងសមស្រប ដើម្បីបង្ហាញអង្គហេតុដែលភស្តុតាងមានបំណងបញ្ជាក់, ច្បាប់អនុញ្ញាត និងពុំមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។ វិធាន ៨៧(៤) តម្រូវថា ភាគីដែលស្នើសុំការដាក់ភស្តុតាង ត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងនេះពុំមាននៅមុនពេលនៃការបើកសវនាការ។ ដូចដែលយើងខ្ញុំនឹងលើកបង្ហាញដូច *ខាងក្រោម* វិវេចនារបស់សាស្ត្រាចារ្យ Chandler បានបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) និងលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤)។ អង្គជំនុំជម្រះសាលាដំបូងគួរទទួលយកឯកសារនេះ និងអនុញ្ញាតឱ្យមេធាវីការពារក្តីប្រើប្រាស់ឯកសារនេះ ក្នុងអំឡុងពេលសួរដេញដោលលោកស្រី Becker។

### ក. វិវេចនារបស់សាស្ត្រាចារ្យ Chandler បានបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) និងគួរត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយក

#### ១. វិវេចនានេះមានភាពពាក់ព័ន្ធ និងពុំច្រំដែល

10. សាស្ត្រាចារ្យ Chandler បានពិនិត្យមើលឡើងវិញ និងបានវិភាគអំពីគុណភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រដែលបាននាំទៅដល់ការបោះពុម្ពផ្សាយសៀវភៅរបស់លោកស្រី Becker ដែលមានចំណងជើងថា *When the War was Over*។ ក្នុងការចាត់ទុកលោកស្រី Becker ជាសាក្សីអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ដោយសារតែការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ [សៀវភៅនានា] ស្តីពីសម័យកាលពាក់ព័ន្ធ [គាត់មាន] ចំណេះដឹងឯកទេសនៅក្នុងវិស័យជំនាញដែលបានស្នើឡើង"[22]។ ដូចដែលយើងនឹងបញ្ជាក់ខាងក្រោមនេះ សាស្ត្រាចារ្យ Chandler បានយល់ឃើញផ្ទុយពីនេះ។

11. សាស្ត្រាចារ្យ Chandler យល់ឃើញថា សៀវភៅរបស់លោកស្រី Becker "ពុំត្រូវបានសរសេរ

---

[22] *ដូចខាងលើដែរ* កថាខណ្ឌ ១៨។

និងពិនិត្យដោយផ្ចិតផ្ចង់ឡើយ”[23]។ គាត់បានសង្កេតឃើញថា លោកស្រី Becker បានយកស្នាដៃជាច្រើនរបស់អ្នកដទៃ ជួនកាលពុំមានការបញ្ជាក់ទៀតផង ហើយលោកស្រី Becker ពុំបានស្រាវជ្រាវប្រធានបទនេះដោយខ្លួនឯងឲ្យបានគ្រប់គ្រាន់ឡើយ។ ពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់លោកស្រី Becker និងវិធីសាស្ត្រស្រាវជ្រាវរបស់លោកស្រី Becker សាស្ត្រាចារ្យ Chandler បានប្រទះឃើញចំណុចខ្វះចន្លោះដូចខាងក្រោម៖

(១) “បញ្ហាដ៏ធ្ងន់ធ្ងរមួយទាក់ទងនឹងការសម្រេចចិត្តរបស់ Becker ក្នុងការសង្កត់ធ្ងន់អំពីកត្តាប្រវត្តិសាស្ត្រ [ចំពោះការងើបឡើងនៃរបបខ្មែរក្រហម] គឺ*ការយល់ដឹងរបស់គាត់អំពីអតីតកាលកម្ពុជា មិនទទួលបានពីការអាន ឬសិក្សាស្រាវជ្រាវឲ្យបានទូលំទូលាយ*”[24]។

(២) ក្នុងផ្នែកស្តីពីសម័យកាលមុនអាណានិគម និងសម័យអង្គរ “[លោកស្រី Becker] បានពឹងផ្អែកយ៉ាងខ្លាំងលើឯកសារជាភាសាអង់គ្លេស ដែលភាគច្រើនជាស្នាដៃបោះពុម្ពផ្សាយពេលថ្មីៗនេះ”[25]។

(៣) ក្នុងការពិពណ៌នារបស់គាត់អំពីសម័យអាណានិគម (ឆ្នាំ ១៨៦៣-១៩៥៤) លោកស្រី Becker “បានខកខានមិនបានពិគ្រោះឯកសារឯកលេខនានាអំពីប្រទេសកម្ពុជា ដែលបាននិពន្ធចាប់តាំងពីប្រទេសកម្ពុជាបានទទួលឯករាជ្យ ដែលភាគច្រើនជាភាសាបារាំង”[26]។

(៤) ការវិភាគនយោបាយរបស់លោកស្រី Becker អំពីសម័យសីហនុ (ឆ្នាំ ១៩៤១-ឆ្នាំ ១៩៧០) មិនមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ លើកលែងតែ “ចំណុចដែលគាត់ប្រើប្រាស់យ៉ាងច្រើននូវអ្វីដែលគាត់ហៅថាជា ស្នាដៃសិក្សាស្រាវជ្រាវរបស់ “អ្នកត្រួសត្រាយផ្លូវ” ដែលជា Ben Kiernan និង Stephen Heder[27]។

---

[23] វិវេចនាដោយ Chandler នៅទំព័រ ៧។

[24] វិវេចនាដោយ Chandler នៅទំព័រ ៧ (គូសបញ្ជាក់បន្ថែម)។

[25] *ដូចខាងលើដែរ* នៅទំព័រ ២-៣។

[26] *ដូចខាងលើដែរ* នៅទំព័រ៣។

[27] *ដូចខាងលើដែរ* ត្រង់ចំណុចនេះ សាស្ត្រាចារ្យ Chandler កត់សម្គាល់ផងដែរថាអ្នកស្រី Becker យកលំនាំតាមស្នាដៃនិពន្ធ Benedict Kiernan “ច្រើនល្មមដែរ” *ដូចខាងលើដែរ* នៅទំព័រ៤។

(៥) សំណេររបស់លោកស្រី Becker ស្ដីពីការវិវឌ្ឍនៃលិទ្ធិជ្រុលនិយមនៅកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និងទសវត្សរ៍ឆ្នាំ ១៩៦០ "មិនមែនជាការសិក្សាស្រាវជ្រាវដោយផ្ទាល់របស់គាត់ទេ"[28]។ ហើយ

(៦) នៅគ្រប់ផ្នែកនៃសៀវភៅនេះ "*ជាពិសេសក្នុងជំពូកស្ដីពីប្រវត្តិសាស្ត្រ* ភាពមិនស្ទាត់ជំនាញភាសាខ្មែររបស់គាត់ ធ្វើឲ្យគាត់សរសេរជំពូកនេះមិនបានល្អ ហើយ*ថ្វីបើស្នាដៃអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត ត្រូវបានដកស្រង់យ៉ាងច្រើន* ...ក៏ដោយ ក៏ជារឿយៗឈ្មោះរបស់អ្នកនិពន្ធមិនមានក្នុងកំណត់ត្រារបស់លោកស្រី Becker ឡើយ"[29]។

12. សាស្ត្រាចារ្យ Chandler សន្និដ្ឋានថា សៀវភៅរបស់លោកស្រី Becker ពុំបានបំពេញតាមអំណះអំណាងរបស់គាត់ដែលថាគាត់ "បានបកស្រាយរាល់ចម្ងល់សំខាន់ៗអំពីរបបខ្មែរក្រហម និងកម្ពុជា" ឡើយ[30]។ ដូចដែលលោកសាស្ត្រាចារ្យ Chandler បានកត់សម្គាល់ អំណះអំណាងនេះ "គឺជាកិច្ចការដ៏លំបាកសម្រាប់បុគ្គលម្នាក់ដែលមិនចេះអានភាសាខ្មែរ ហើយមិនបានសិក្សាឲ្យបានជ្រួតជ្រាប (យ៉ាងហោចណាស់ចំនួន ៦ ឆ្នាំ) នូវឯកសារដ៏សម្បូរបែបដែលអាចរកបាន ប៉ុន្តែជាឯកសារប្រភពដើម និងឯកសារបន្ទាប់បន្សំ ដែលមានលក្ខណៈផ្ទុយគ្នាច្រើន"[31]។ សេចក្ដីសន្និដ្ឋានរបស់សាស្ត្រាចារ្យ Chandler ពាក់ព័ន្ធផ្ទាល់ទៅនឹងឋានៈ និងភាពអាចជឿជាក់បានរបស់លោកស្រី

---

[28] *ដូចខាងលើដែរ* នៅទំព័រ៥ (គូសបញ្ជាក់បន្ថែម)។ សាស្ត្រាចារ្យ Chandler កត់សម្គាល់ថាស្នាដៃនិពន្ធរបស់អ្នកស្រី Becker បានដកស្រង់យ៉ាងច្រើនពីស្នាដៃនិពន្ធរបស់អ្នកសិក្សាស្រាវជ្រាវ ដូចជា Benedict Kiernan, Michael Vickery និង Stephen Heder ។

[29] *ដូចខាងលើដែរ* នៅទំព័រ ៧ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* នៅទំព័រ៣ "ទំនាក់ទំនងជាក់លាក់ [រវាងប្រពៃណីនៃការលួចប្លន់ ជំនឿនៃការផ្លាស់ប្ដូរសង្គម ការបះបោររបស់កសិករ និងឫសគល់នៃលទ្ធិជ្រុលនិយមរបស់ប្រជាជនកម្ពុជា ត្រូវបាន Vickery ពិនិត្យមើលដោយលម្អិតក្នុងសៀវភៅដែលមានចំណងជើងថា <u>ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៨២</u> *ដែលបានយោងទៅក្នុងគន្ថនិទ្ទេសរបស់ Becker ប៉ុន្តែមិនមានយោងក្នុងកំណត់ត្រារបស់គាត់ឡើយ*" (គូសបញ្ជាក់បន្ថែម)។ *ដូចខាងលើដែរ* នៅទំព័រ៧៖ "គាត់គប្បីយោងឈ្មោះអ្នកនិពន្ធ Michael Vickery ជាច្រើនដងនៅក្នុងអត្ថបទ (ឧទាហរណ៍ ទំព័រ ១០៩, ១៣៤, ២៥០ និង ២៥៤) ដោយសារវាត្រូវបានមើលឃើញថា Becker លើកពិពណ៌នាឡើងវិញនូវស្នាដៃសិក្សាស្រាវជ្រាវ "ត្រួសត្រាយផ្លូវ" របស់គាត់។(គូសបញ្ជាក់បន្ថែម)។

[30] *ដូចខាងលើដែរ* នៅទំព័រ៨ *សូមមើលផងដែរ* Elizabeth Backer នៅពេលដែលសង្គ្រាមផុតរលត់ទៅ (Simon & Schuster, បោះពុម្ពផ្សាយលើកទី១ ក្នុងឆ្នាំ១៩៨៦)។ Elizabeth Backer នៅពេលដែលសង្គ្រាមផុតរលត់ទៅ (Public Affairs, បោះពុម្ពផ្សាយលើកទី២ ក្នុងឆ្នាំ១៩៩៨) ឯកសារ E3/20។

[31] វិវេចនាដោយ Chandler នៅទំព័រ ៨។

Becker ក្នុងនាមជាសាក្សីអ្នកជំនាញ និងការវាយតម្លៃអំពីភាពទុកចិត្តបាន និងតម្លៃនៃសក្ខីកម្មរបស់គាត់។

## ២. វិវេចនានេះត្រូវបានទទួលក្នុងរយៈពេលមួយសមស្រប

13. ទោះបីជាអត្ថបទនេះអាចជាឯកសារសាធារណៈចាប់តាំងពីឆ្នាំ ១៩៨៦[32] ដូចមានបញ្ជាក់យ៉ាងពិស្តារខាងលើមកក្តី ក៏មេធាវីការពារក្តីត្រូវប្រើពេលដ៏ច្រើនទើបរកឃើញឯកសារនេះ។ ឯកសារវិវេចនានេះត្រូវបានសរសេរមុនពេលមានការប្រើបច្ចេកវិទ្យាកំព្យូទ័រជាទូទៅ និងតាមអ្វីដែលមេធាវីការពារក្តីបានដឹង ឯកសារនេះមានតែជាឯកសារលើក្រដាសប៉ុណ្ណោះ។ នៅពេលរកឃើញអត្ថបទនេះជាឯកសារលើក្រដាស មេធាវីការពារក្តីបានដាក់សំណើសុំនេះយ៉ាងលឿនបំផុតតាមតែអាចធ្វើទៅបាន បន្ទាប់ពីដាក់បញ្ចូលឯកសារនេះទៅក្នុងឃ្លាំងផ្ទុកឯកសាររួម និងសុំឲ្យមានការបកប្រែទៅជាភាសាខ្មែរ និងភាសាបារាំង។ កាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាង ដែលអាចរកបានតាមបច្ចេកទេសមុនពេលសវនាការ ប្រើសិនបើការទទួលយកភស្តុតាងនោះមិន ប៉ះពាល់ដល់ប្រយោជន៍របស់ភាគីដទៃ និងប្រសិនបើភស្តុតាងនោះត្រូវបានដាក់ជូនត្រឹមត្រូវមុនពេលសាក្សីធ្វើសក្ខីកម្ម[33]។ នៅទីនេះ ដោយមានមូលហេតុដូចខាងក្រោម គ្មានភាគីណាមួយនឹងត្រូវរងព្យសនកម្មពីការដែលមេធាវីការពារក្តីប្រើវិវេចនានេះទេ៖

ក. មេធាវីការពារក្តីស្នើសុំឲ្យតុលាការទទួលយកតែឯកសារមួយ។

ខ. ឯកសារនេះមានចំនួនតិចជាង ១០ទំព័រ។

គ. មុនពេលអ្នកស្រី Becker មកធ្វើសក្ខីកម្ម ភាគីទាំងអស់មានពេលគ្រប់គ្រាន់ក្នុងការពិនិត្យមើល និងវាយតម្លៃឯកសារនេះ។ និង

ឃ. មានឱកាសគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងផ្តល់ឯកសារនេះជូនអ្នកស្រី Becker មុនពេលគាត់មកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

## ៣. វិវេចនានេះសមស្របក្នុងការបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺ

[32] ចូរអានកថាខណ្ឌទី ៧ នៃអនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១២។

[33] ដូចលេខយោង កថាខណ្ឌទី ៨។

14. វិវេចនារបស់សាស្ត្រាចារ្យ Chandler គឺជាឧបករណ៍ "សមស្រប" សំរាប់ការវាយតម្លៃពីភាពអាចជឿជាក់បានលើអ្នកស្រី Becker ក្នុងឋានៈជាសាក្សី[34] ផ្អែកតាមមូលហេតុដូចខាងក្រោមនេះ៖

ក. សាស្ត្រាចារ្យ Chandler បានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូងចំនួន ៦ ថ្ងៃ ក្នុងឋានៈជាអ្នកជំនាញក្នុងសំណុំរឿង ០០២/០១[35] និងក្នុងឋានៈជាអ្នកជំនាញក្នុងរឿងក្តី ០០១[36]។

ខ. សាស្ត្រាចារ្យ Chandler ជាប្រវត្តិវិទូចូលនិវត្តន៍ ដែលបង្រៀនប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យ Monash នៅប្រទេសអូស្ត្រាលី[37]។

គ. សាស្ត្រាចារ្យ Chandler មានសញ្ញាប័ត្រថ្នាក់បណ្ឌិត (PhD)[38] ជំនាញខាងប្រវត្តិសាស្ត្រកម្ពុជា[39]។

ឃ. សាស្ត្រាចារ្យ Chandlerចេះនិយាយភាសាខ្មែរ[40] និងមានការយល់ដឹងអំពីវប្បធម៌ខ្មែរ។ និង

ង. ក្នុងរយៈពេលបីទសវត្សរ៍ សាស្ត្រាចារ្យ Chandler បានសរសេរសៀវភៅបួន និងអត្ថបទជាច្រើនអំពីសម័យកម្ពុជាប្រជាធិបតេយ្យ[41]។

15. មេធាវីការពារក្តីមិនទទួលស្គាល់ថា សក្ខីកម្ម និងភស្តុតាងរបស់សាស្ត្រាចារ្យ Chandler មិនអាចជំទាស់បាននោះទេ[42]។ ទោះបីជាយ៉ាងណាក្តី សាស្ត្រាចារ្យ Chandler ជាប្រភពព័ត៌មានដ៏សំខាន់

---

[34] ចូរអានវិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុង។

[35] ប្រតិចារិក ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/91.1; ប្រតិចារិក ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/92.1; ប្រតិចារិក ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/93.1; ប្រតិចារិក ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/94.1; ប្រតិចារិក ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/95.1; ប្រតិចារិក ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1;

[36] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសជ ប្រតិចារិក ថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០០៩ ឯកសារ E1/59.1;

[37] ប្រតិចារិក ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/91.1 ទំព័រ ១០។

[38] ដូចកថាខណ្ឌ ១៩។

[39] ដូចកថាខណ្ឌ ១៩។

[40] ដូចកថាខណ្ឌ ១២។

[41] ដូចកថាខណ្ឌ ១៣-១៧។

[42] ប្រតិចារិក ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/94.1; ប្រតិចារិក ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ E1/95.1 ដែលក្នុងនោះមេធាវីការពារក្តីបានសួរដេញដោលសាស្ត្រាចារ្យ Chandler អំពីការស្រាវជ្រាវ និងវិធីសាស្ត្ររបស់គាត់។

អំពីកម្ពុជា ដែលបានវិភាគពីសៀវភៅរបស់អ្នកស្រី Becker និងដូចបានកត់សំគាល់ខាងលើ គាត់បានកត់សំគាល់ឃើញកំហុសឆ្គងជាច្រើនក្នុងវិធីសាស្ត្រ និងខ្លឹមសារនៃសៀវភៅរបស់អ្នកស្រី Becker។

### ៤. វិវេចនាត្រូវបានច្បាប់អនុញ្ញាតឲ្យប្រើ

16. វិវេចនារបស់សាស្ត្រាចារ្យ Chandler ត្រូវបានអនុញ្ញាតដោយច្បាប់បង្កើត អ.វ.ត.ក និងច្បាប់កម្ពុជា។ ឯកសារនេះមិនត្រូវបានបង្កើតឡើង ឬទទួលបាន ដោយមធ្យោបាយមិនស្របច្បាប់ឡើយ។

### ៥. មេធាវីមិនមានចេតនាប្រើវិវេចនានេះ ដើម្បីអូសបន្លាយដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ទេ

17. មេធាវីមិនមានចេតនាប្រើវិវេចនារបស់សាស្ត្រាចារ្យ Chandler នេះ ដើម្បីអូសបន្លាយដំណើរការនីតិវិធី ឬធ្វើឲ្យដំណើរការនីតិវិធីប្រព្រឹត្តទៅដោយឥតបានការឡើយ។ វិវេចនានេះទាក់ទងផ្ទាល់ទៅនឹងខ្លឹមសារ និងមូលដ្ឋាននៃសក្ខីកម្មរបស់អ្នកស្រី Becker។ វិវេចនានេះនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត និងការវាយតម្លៃពីភាពអាចជឿជាក់បានរបស់អ្នកស្រី Becker។

### ខ. វិវេចនារបស់សាស្ត្រាចារ្យ Chandler បំពេញតាមលក្ខខណ្ឌនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

### ១. មេធាវីមិនមានវិវេចនានេះបានមុនពេលបើកសវនាការ

18. ដោយគោរពតាមកាតព្វកិច្ចស្តីពីការយកចិត្តទុកដាក់ត្រឹមត្រូវ មេធាវីការពារក្តីបានពិនិត្យឯកសារសម្ភារៈទាំងអស់ ដែលខ្លួនមាន ដែលថាមានការពាក់ព័ន្ធទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញម្នាក់ៗ។ ដូចបានបញ្ជាក់ខាងលើ មេធាវីការពារក្តីបានស្រាវជ្រាវរកវិវេចនារបស់សាស្ត្រាចារ្យ Chandler ប៉ុន្តែកាលពីមុនមិនអាចរកឃើញឯកសារនេះ ឬព័ត៌មានត្រឹមត្រូវអំពីទីកន្លែងបោះពុម្ពផ្សាយឯកសារនេះទេ ទោះបីជាបានធ្វើការទាក់ទងផ្ទាល់ជាមួយសាស្ត្រាចារ្យ Chandler និងធ្វើការស្វែងរកតាមអ៊ិនធឺណែត និងទិន្នន័យរូបវន្តក៏ដោយ។

19. ការិយាល័យសហព្រះរាជអាជ្ញា បានបញ្ជាក់ថា មិនគប្បីដកចេញឯកសារសម្ភារៈ ដោយសារតែឯកសារសម្ភារៈនោះមិនត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលមុនបើក

សវនាការទេ ឬមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីឯកសាររបស់ភាគី តាមវិធាន ៨០ ឡើយ[43]។ លោកសហព្រះរាជអាជ្ញារង William Smith បានបញ្ជាក់នៅក្នុងសវនាការថា៖ "យើងយល់ស្របថា... អាចមានកាលៈទេសៈដែលឯកសារអាចក្លាយទៅជាមានសារសំខាន់នៅពេលក្រោយ ពាក់ព័ន្ធទៅនឹងការធ្វើតែស្ត [sic] ភាពអាចជឿជាក់បាននៃសាក្សី... យើងមិនស្នើឲ្យដាក់រាល់ឯកសារទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះទេ"[44]។ ក្នុងករណីនេះ ទោះបីជាវិវេចនារបស់សាស្ត្រាចារ្យ Chandler មានអត្ថិភាពមុនពេលបើកសវនាការក្តី ក៏មេធាវីការពារក្តីមិនបានកាន់កាប់ឯកសារនេះទេ ទោះបីជាខ្លួនបានប្រឹងប្រែងស្រាវជ្រាវរកអស់ពីលទ្ធភាពក្តី។ ដូច្នេះ ក្នុងអត្ថន័យនៃវិធាន ៨៧ (៤)[45] មេធាវីការពារក្តី "មិនមាន" ឯកសារនេះឡើយ មុនពេលបើកសវនាការ។ ដោយសារមេធាវីការពារក្តីបានផ្តល់ឯកសារវិវេចនារបស់សាស្ត្រាចារ្យ Chandler ទាំងបីភាសាជូនអង្គជំនុំជម្រះសាលាដំបូង និងភាគី មុនពេលអ្នកស្រី Becker មកផ្តល់សក្ខីកម្ម គ្មានភាគីណាមួយនឹងរងព្យសនកម្មពីការទទួលយកឯកសារនេះឡើយ។

### III. សេចក្តីសន្និដ្ឋាន

20. អ្នកស្រី Becker ជាអ្នកសារព័ត៌មាន ដែលបានយកស្នាដៃជាច្រើនរបស់អ្នកដទៃមកសរសេរបញ្ចូលក្នុងសៀវភៅរបស់ខ្លួន។ សៀវភៅនេះមិនមែនជាលទ្ធផលចេញពីកិច្ចប្រឹងប្រែងផ្នែកសិក្សាស្រាវជ្រាវ និងខាងវិទ្យាសាស្ត្រឡើយ[46]។ មេធាវីការពារក្តីបានបញ្ជាក់ថា អង្គជំនុំជម្រះសាលា

---

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់លោក អៀង សារី និង នួន ជា តាមវិធាន ៨៧ ដើម្បីប្រើវត្ថុ/សម្ភារៈក្នុងពេលសួរដេញដោលលោក Philip Short ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១២ ឯកសារ E226/2 កថាខណ្ឌ ១។

[44] ប្រតិចារិក ថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១២ ឯកសារ E1/60 កថាខណ្ឌ ៥១។

[45] ដោយពិចារណាយុត្តាធិការ ICTY និង ICTR អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "សញ្ញាណនៃការអាចរកបាននូវភស្តុតាងត្រូវបានភ្ជាប់ទៅនឹងការអនុវត្តការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវ"។ សេចក្តីសម្រេចស្តីពីការដាក់ឯកសារថ្មី និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២៣។

[46] មេធាវីការពារក្តីកត់សំគាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួននឹងមិនកោះអញ្ជើញលោក Benedict Kiernan ឬ លោក Michael Vickery មកធ្វើជាសាក្សីក្នុងរឿងក្តី 002/01 ទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគប្បីបដិសេធចោលរាល់ផ្នែកនៃសៀវភៅ ឬសក្ខីកម្មរបស់អ្នកស្រី Becker ដែលយោងទៅរក ឬផ្អែកលើស្នាដៃរបស់បញ្ញវ័ន្តទាំងពីររូបនេះ។ *ចូរអាន* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការចង្អុលបង្ហាញជាបឋមនូវបុគ្គលដែលតុលាការត្រូវស្តាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការ ការជម្លៀសប្រជាជនក្នុងរឿងក្តី ០០២/០១" ចុះថ្ងៃទី ២ ខែតុលា

ដំបូងមិនគប្បីចាត់ទុកអ្នកស្រី Becker ជាសាក្សីអ្នកជំនាញទេ ដោយសារមូលហេតុផ្សេងៗច្បាស់លាស់ដែលលោកសាស្ត្រាចារ្យ Chandler បានបញ្ជាក់នៅក្នុងវិវេចនា ដោយលោកសាស្ត្រាចារ្យបានលើកឡើងថា៖ អ្នកស្រី Becker មិនបានធ្វើការស្រាវជ្រាវដោយខ្លួនឯងទេ គាត់បានពឹងផ្អែកលើស្នាដៃរបស់អ្នកដទៃ គាត់មិនបានបញ្ជាក់ពីប្រភពនានាក្នុងសៀវភៅគាត់ទេ ហើយគាត់គ្មានសមត្ថភាពនិយាយភាសាខ្មែរទេ។ សាស្ត្រាចារ្យ Chandler ជាបញ្ញវ័ន្តដែលបានបោះពុម្ពផ្សាយទូលំទូលាយអំពីប្រវត្តិសាស្ត្រកម្ពុជា និងបានធ្វើការវិភាគដ៏លំអិតអំពីស្នាដៃរបស់អ្នកស្រី Becker។ វិវេចនានេះមានការពាក់ព័ន្ធទៅនឹងការកំណត់វិសាលភាព និងកម្រិតនៃ "ការយល់ដឹងជាលក្ខណៈឯកទេសរបស់អ្នកស្រី Becker អំពីសម័យកម្ពុជាប្រជាធិបតេយ្យ និងការវាយតម្លៃអំពីភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានរបស់គាត់ក្នុងឋានៈជាសាក្សីអ្នកជំនាញ។ អង្គជំនុំជម្រះមិនត្រូវបដិសេធវិវេចនានេះ ដោយគ្រាន់តែសំអាងថា ឯកសារនេះត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៨៦ មុនពេលបើកការកាត់ក្ដីនេះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះត្រូវតែទទួលយកវិវេចនានេះដើម្បីអនុញ្ញាតឲ្យមានការវាយតម្លៃពេញលេញលើសក្ខីកម្ម និងភស្តុតាងរបស់អ្នកស្រី Becker។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធវិវេចនារបស់សាស្ត្រាចារ្យ Chandler អង្គជំនុំជម្រះសាលាដំបូងនឹងបង្ហាញដល់សាធារណជន និងភាគីថាខ្លួន ថាខ្លួនគ្មានការប្ដេជ្ញាចិត្តក្នុងការបញ្ជាក់ការពិតក្នុងសំណុំរឿង ០០២/០១ និងមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ភាគីឡើយ។

**អាស្រ័យដោយមូលហេតុដូចបានរៀបរាប់ខាងលើ** មេធាវីការពារក្ដីសូមស្នើដាក់វិវេចនារបស់របស់សាស្ត្រាចារ្យ Chandler ដែលមានចំណងជើងថា *Requiem for the 1970s៖ សៀវភៅរបស់ Elizabeth Becker When the War Was Over* ជូនអង្គជំនុំជម្រះសាលាដំបូង និងសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីប្រើវិវេចនានេះក្នុងអំឡុងពេលសួរដេញដោលលោកស្រី Becker។

---

ឆ្នាំ ២០១២ កថាខណ្ឌ ៦។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សំណើផ្ដល់សក្ខីកម្មលោក Benedict KIERNAN ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១២

សហមេធាវីការពារក្តីលោក អៀង សារី

អាង ឧត្តម Michael G. KARNAVAS